លេខ ១០២៦ ក.យ.ធ ភ្នំពេញ, ថ្ងៃទី ២៦ ខែតុលា ឆ្នាំ១៩៨២

# សារាចរ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## គោរពជូន ៖

- សមមិត្ត ប្រធាន អនុប្រធាន ចៅក្រម នៃតុលាការប្រជាជនខេត្ត-ក្រុង

- សមមិត្តរដ្ឋអាជ្ញាអបតុលាការប្រជាជន ខេត្ត-ក្រុង

**កម្មវត្ថុ** ៖ អំពីការអនុវត្តន៍សាលក្រម ផ្នែកព្រហ្មទណ្ឌ

ខ្ញុំសូមសមមិត្តចាប់រម្មណ៍ថា តាមអញ្ញត្តិនៃមាត្រា ១១ នៃច្បាយ ចុះថ្ង ទី ១០ - ២ - ៨២ ស្តីពីការចាត់តាំងអង្គការតុលាការ និង អយ្យការ គ្រប់សាល- ក្រុមរបស់តុលាការប្រជាជនខេត្ត-ក្រុង តាមគោលការណ៍ ត្រូវជំនុំជំរះចំពោះ ឬខគូភាគី ។

ដោយតុលាការប្រជាជនក្រុង - ខេត្ត ធ្វើការជំនុំជំរះជាលើកទី ១ និង " ជាចុងក្រោយបង្អស់ សាលក្រមចំពោះមុខ ត្រូវអនុវត្តភ្លាមៗ លើលងតែក្នុង ករណីសាលក្រមកាត់ទោសប្រហារជីវិត ។

ផ្ទុយទៅវិញ សាលក្រមកំបាំងមុខ មិនអាចយកទៅអនុវត្តបានឡើយ។

គូភាគី អាចប្តឹងជំទាស់បានក្នុងរយៈ ១៥ ថ្ងៃ ដោយគិតពីថ្ងៃដែលបានពយដំណឹង ពីសាលក្រមនោះ ដល់គូភាគីផ្ទាល់ខ្លួន ឬ ដល់ទីលំនៅរបស់គូភាគី។

ជាការពិតណាស់ ផ្នែកអនុវត្តសាលក្រម ជាភាគមួយមានសារៈសំខាន់ នៃនីតិវិធីព្រហ្មទណ្ឌ ពីព្រោះការអនុវត្តន៍សាលក្រម អាចធានាដល់ប្រសិទ្ធិភាព នៃការជំនុំជំរះរបស់តុលាការ និងធ្វើឱយប្រជាជនមានជំនឿលើរដ្ឋអំណាចបដិវត្ត។

ដោយផ្អែកលើគំនិតនេះ គ្រប់អង្គការ និង ក្របខ័ណ្ឌមានសមត្ថកិច្ច ក្នុងការអនុវត្តន៍សាលក្រម ត្រូវយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចតទៅ៖

### I - ការអនុវត្តន៍សាលក្រមលើទណ្ឌិត ដែលត្រូវផ្តន្ទាទោសជាកពន្ធនាគារ

ការអនុវត្តន៍សាលក្រម លើទណ្ឌិត ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ជាបឋម ឃើញដូចជាការមួយមានលក្ខណៈងាយស្រួល ប៉ុន្តែក្នុងការប្រតិបត្តិ ច្បាស់ជាជួបប្រទះនឹងការលំបាកមិនខាន ។

ដូចនេះ ត្រូវយកចិត្តទុកដាក់ក្នុងករណីដូចតទៅ ៖

១ - ករណីជនជាប់ឃុំឃាំង

ប្រសិនបើជនជាប់ឃុំឃាំង បានត្រូវតុលាការជំនុំជំរះ ឱ្យរួចខ្លួនពីបទ ឬ ត្រូវផ្តន្ទាទោស តែទោសនោះត្រូវព្យួរ ប្រធានតុលាការ ក្រោយជំនុំជំរះ ត្រូវធ្វើដីកាមួយ បង្គាប់ទៅប្រធានមន្ទីរឃុំឃាំង ឱ្យដោះលែងជននោះ

មួយរំពេច ប្រសិនបើជននោះ គ្មានហេតុភេទអ្វីផ្សេងគួរឲយឃុំឃាំង បន្តទៀត។ ឯសេចក្ដីចម្លងសាលក្រម អាចផ្ញើទៅឱ្យប្រធានមន្ទីរឃុំឃាំង ដើម្បីបានចាត់ការតាមច្បាប់តទៅ។

អយ្យការ និង តុលាការប្រជាជនត្រូវមកទំនាក់ទំនងជានិច្ចជាមួយរដ្ឋអំណាចមូលដ្ឋាន ដែលជនទទួលការព្យួរទោសស្នាក់នៅ ឬ ជាមួយស្ថាប័ន ដែលជននោះស្ថិតក្រោមឱវាទ ដើម្បីត្រួតពិនិត្យសកម្មភាពរបស់ជននោះ ក្នុងរយៈពេលសាកល្បង។

ប្រសិនបើ ជនជាប់ឃុំឃាំង ត្រូវតុលាការជំនុំជំរះផ្ដន្ទាទោសដាក់ពន្ធនាគារ ប្រធានតុលាការ, ក្នុងករណីនេះ ត្រូវផ្ញើសំរង់សាលក្រមទៅឱ្យ ប្រធានមន្ទីរឃុំឃាំង ដើម្បីអនុវត្ត។

២ - ករណីជនជាប់ចោទនៅក្រៅឃុំ

ក្នុងករណី ជនជាប់ចោទនៅក្រឃុំ មានសាលក្រមស្ថាព ផ្ដន្ទាទោស ដាក់ពន្ធនាគារ ប្រធានតុលាការ ត្រូវរើសំរង់សាលក្រមទោប្រធានសន្តិសុខមូលដ្ឋានដែលជននោះស្នាក់នៅ ដើម្បីអនុវត្ត។ ប្រសិនបើទណ្ឌិតជាកម្មាភិបាល ឬ បុគ្គលិក ឬ កម្មកររបស់រដ្ឋ ប្រធានតុលាការ ត្រូវផ្ញើសំរង់ សាលក្រមមួយច្បាប់ទៀតទៅស្ថាប័ន ឬ អង្គការរដ្ឋ ក្រោមឱវាទ ដើម្បីជាពត៌មាន។

ក្នុងករណីដែលតុលាការជំនុំជំរះ រួចខ្លួន ឬ ផ្ដន្ទាទេសដាក់ពន្ធនាគារ តែទោសនោះត្រូវព្យួរ ជននោះត្រូវបានតុលាការចេញសំរង់សាលក្រមឱ្យ ដើម្បីទុកប្រើការតាមច្បាប់តទៅ។

## កំណត់សំគាល់

### ក - អំពីការផ្អាកការអនុវត្តន៍សាលក្រម

ប្រធានតុលាការ ប្រសិនបើ ពិនិត្យលើកំណត់ហេតុ ដែលធ្វើឡើងដោយប្រធានសន្តិសុខ ឃើញថាការអនុវត្តន៍សាលក្រម បណ្ដាលឱ្យប៉ះពាល់ ធ្ងន់ធ្ងរ ដល់អនាគតរបស់គ្រួសារទណ្ឌិត (ឧទាហរណ៍ ទណ្ឌិតជាស្ត្រីទុគ៌ត មានកូនតូចៗជាច្រើន រស់នៅក្នុងបន្ទុក) ឬ បណ្ដាលឱ្យប៉ះពាល់ ដល់អាយុជីវិត របស់ទណ្ឌិត (ទណ្ឌិតជាអ្នកមានជម្ងឺ កំពុងព្យាបាលក្នុងមន្ទីរពេទ្យ ស្ត្រីមាន ផ្ទៃពោះគ្រប់ខែ . . . ) ដោយមានការយល់ព្រមពីរដ្ឋអាជ្ញាផង អាចបញ្ជាឱ្យផ្អាក ការអនុវត្តន៍សាលក្រម ដែលមានថិរវេលាចាប់ពី ១ខែ ទៅ ៦ខែ។

### ខ - អំពីការបញ្ចប់ការអនុវត្តន៍សាលក្រម

មរណភាព របស់ទណ្ឌិត ចាត់ចូលក្នុងករណីបញ្ចប់ការអនុវត្តន៍សាលក្រម។ ក្នុងករណីនេះ សន្តិសុខត្រូវធ្វើកំណត់ហេតុមួយ បញ្ជូនជាមួយលិខិតសំគាល់ មរណភាពនៃទណ្ឌិត ទៅតុលាការប្រជាជន។ ប្រធានតុលាការ ដោយមានយោបល់យល់ព្រមពីរដ្ឋអាជ្ញាផង ចេញដីកាដោយឯងៗ បញ្ឈប់ការអនុវត្តន៍ សាលក្រម។

### គ - ហេតុបច្ច័យរវាងទណ្ឌកម្មលើរូបកាយ និង ការជួស ជុលភាពអន្តរាយ

មរណភាពរបស់ទណ្ឌិត រំលត់តែទណ្ឌកម្មលើរូបកាយ មិនអាចបំបាត់ការ ជួសជុលភាពអន្តរាយ បានឡើយ ។ ដូចនេះ កម្មាភិបាលតុល ាការប្រជាជន ទទួលបន្ទុកអនុវត្តន៍ សាលក្រម ត្រូវបំពេញការងាររបស់ខ្លួនតាមធម្មតា។

II - ការអនុវត្តន៍សាលក្រម លើទណ្ឌិត ដែលត្រូវកាត់ទោសប្រហារជីវិត

តាមគោលការណ៍ ទណ្ឌិតដែលត្រូវកាត់ទោសប្រហារជីវិត មានសិទ្ធិសុំអនុគ្រោះទោសទៅក្រុមប្រឹក្សារដ្ឋ ក្នុងរយៈពេល ៧ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រម ( មាត្រា ១០ នៃច្បាប់ចុះថ្ងៃ ១០-២-៩២ អង្គការតុលាការ និង អយ្យការ)។

កាលបើការសុំអនុគ្រោះទោសនោះ ត្រូវបដិសេធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជូនពត៌មាននោះភ្លាមតាមលិខិតទៅសាមីប្រធានតុលាការ។

ឯការអនុត្តន៍សាលក្រម ក៏ចាប់ប្រព្រឹត្តឡើង ដោយធ្វើជាពីរដំណាក់កាល

## តំណាក់កាលទី១ : អំពីវិធានការរៀបចំ

ជាបឋម ប្រធានតុលាការប្រជាជន ត្រូវស្នើសុំគណៈកម្មាធិការប្រជាជន បដិវត្តខេត្ត ឬ ក្រុង ចាត់តាំងជាបន្ទាន់ នូវគណៈកម្មការមួយ ទទួលបន្ទុកអនុវត្តន៍ សាលក្រមប្រហារជីវិត ដែលមានសមាសភាព ដូចតទៅៈ

| | |
|---|---|
| - តំណាងនគរបាលខេត្ត ឬ ក្រុង មួយរូប | ប្រធាន |
| - តំណាងតុលាការប្រជាជន មួយ រូប | សមាជិក |
| - តំណាងអយ្យការ មួយរូប | សមាជិក |
| - តំណាងមន្ទីរពន្ធនាគារ មួយរូប | សមាជិក |
| - គ្រូពេទ្យ មួយរូប | សមាជិក |

គណៈកម្មការនេះ មានភារកិច្ចកំណត់អំពីថ្ងៃ ទីកន្លែងប្រហារជីវិត ព្រមទាំងកំណត់ នូវវិធានការផ្សេងៗ ស្តីពីការដឹកជញ្ជូនទណ្ឌិត ពីការចាត់ចែង សន្តិសុខនៅកន្លែងប្រហារ ពីការចាត់តាំងក្រុមប្រហារ។ ល ។ និង ។ ល។

ថ្ងៃប្រហារជីវិតនៃទណ្ឌិត មិនត្រូវធ្វើឡើងឱយជួនទៅលើថ្ងៃបុណ្យប្រជាប្រិយ ថ្ងៃបុណ្យជាតិ ឬ ថ្ងៃបុណ្យអន្តរជាតិធំៗ ដូចជា ថ្ងៃបុណ្យទិវាពលកម្មអន្តរជាតិ ថ្ងៃបុណ្យសិទ្ធិមនុស្ស ជាដើម។

## ដំណាក់កាល ទី ២ ÷ អំពីការប្រហារជីវិត

នៅព្រឹកថ្ងៃប្រហារជីវិត វេលាម៉ោង ៤ ភ្លឺ ប្រធានតុលាការ និង គណៈកម្មការប្រហារជីវិត ត្រូវទៅកាន់ពន្ធនាគារ ដើម្បីជូនដំណឹងដល់ទណ្ឌិត អំពីការបដិសេធការសុំអនុគ្រោះទោស របស់ក្រុមប្រឹក្សារដ្ឋ និង អំពីការត្រូវអនុវត្តសាលក្រម ដែលបានផ្តន្ទាទោសលើរូបទណ្ឌិតនោះ។ ប្រធានតុលាការ ត្រូវអានសេចក្តីសំរេចបដិសេធពាក្យសុំអនុគ្រោះទោស ឱ្យទណ្ឌិតស្តាប់ នៅចំពោះមុខគណៈកម្មការប្រហារជីវិត។ ក្រោយពីអានសេចក្តីសំរេចបដិសេធចប់ភ្លាម ប្រធានតុលាការ ត្រូវជូនដំណឹងដល់ទណ្ឌិតថា អាចផ្តាំផ្ញើ ឬ ផ្ញើបណ្តាំ ជាចុងក្រោយបង្អស់ ដល់គ្រួសាររបស់ខ្លួនបាន។ ប្រសិនបើមិនចេះសរសេរទណ្ឌិត អាចធ្វើបណ្តាំដោយផ្ទាល់មាត់បាន ហើយបណ្តាំនោះ ប្រធានតុលាការ ត្រូវកត់ត្រាទុកឱ្យបានត្រឹមត្រូវបំផុត។ បន្ទាប់មក ប្រធានតុលាការ ក្នុងនាមនៃ គណៈកម្មការ បង្គាប់ឱ្យទណ្ឌិតផ្តិតម្រាមដៃទាំងដប់ លើក្រដាសពិសេសសំរាប់ កិច្ចការនោះ។

ប្រធានពន្ធនាគា ត្រូវបំរុងរបបអាហារឱ្យបរិបូណ៌ តាមលទ្ធភាពដែល អាចធ្វើបាន ដើម្បីឱ្យទណ្ឌិតបរិភោគ មុនពេលបញ្ជូនទៅកន្លែងប្រហារជីវិត។

ហាមផ្ដាច់ មិនអនុញ្ញាតឱ្យជនណាមួយ ក្រៅពីគណៈកម្មការប្រហារជីវិតទាក់ទង ឬ សួរសុខទុក្ខដល់ទណ្ឌិតឡើយ។ ប៉ុន្តែ អាចអនុញ្ញាតឱ្យទណ្ឌិត ជួបបានជាមួយអាចារ្យ ឬ សង្ឃ តាមសាសនា ដែលទណ្ឌិតធ្លាប់គោរព។

គណៈកម្មការប្រហារជីវិត ត្រូវធ្វើកំណត់ហេតុមួយ ស្ដីពីសកម្មភាពខាងលើនេះ។

បន្ទាប់មក ទណ្ឌិតបានត្រូវនាំចេញពីពន្ធនាគារភ្លាម តាមរថយន្តបិទជិតមួយ ជាមួយកងការពារប្រដាប់អាវុធ។

នៅកន្លែងប្រហារជីវិត គ្រប់សមាជិកនៃគណៈកម្មការប្រហារជីវិត ត្រូវមានវត្តមានជាចាំបាច់ ព្រមទាំងតំណាងរដ្ឋអំណាចមូលដ្ឋានផង។ ប្រជាជនដែលស្ថិតនៅជិតបរិវេណកន្លែងប្រហារជីវិតនោះប្រជាជន អាចអនុញ្ញាតឱ្យចូលមើលការប្រហារជីវិតនោះបាន ក្នុងលក្ខណៈដែលរបៀបរៀបរយសាធារណៈអាចត្រូវធានាបាន ប៉ុន្តែហាមផ្ដាច់ មិនឱ្យប្រជាជនដែលចូលមើលនោះ ថត ឬ ថត ជាខ្សែភាពយន្ត នូវវិការដ្ឋាន នៃការប្រហារជីវិតនោះឡើយ។ តមក ត្រូវ ទណ្ឌិតទៅកាន់កន្លែងប្រហារជីវិត ដោយនៅទីនោះ កងប្រហារ បានឈរប្រុងប្រៀបជាស្រេច។ ប្រធានតុលាការ អានដោយសង្ខេប នូវសាលក្រមដែលកាត់ទោសប្រហារជីវិតលើរូបបណ្ឌិត ព្រមទាំងអានសេចក្ដីសំរេចបដិសេធពាក្យ សុំអនុគ្រោះទោសផង រួចទណ្ឌិតក៏ត្រូវនាំដោយអហឹង្សាទៅចងភ្ជាប់នឹងបង្គោល ដែលបានរៀបទុកជាមុនបែរមុខទៅរកក្រុមប្រហារ ដួលក្នុងកសមាជិក ៥ រូប ហើយទណ្ឌិតក៏ត្រូវបិទភ្នែកដោយផ្ទាំងក្រណាត់ លើកលែងតែក្នុងករណី ដែលទណ្ឌិតនេះ សុំកុំឱ្យបិទភ្នែកខ្លួន។

ប្រធានក្រុមប្រហារ ឈចម្ងាយ ៤ ជំហានពីខាងស្ដាំដូចប្រហារ លើកដៃម្ខាងឡើងជាសញ្ញា។ សមាជិកក្រុមប្រហារ ៥ រូប តាមសញ្ញានេះ តម្រង់ អាវុធរៀងៗ ខ្លួន ទៅចំទ្រូងរបស់ទណ្ឌិត ប្រធានក្រុមប្រហារលើកដៃមួយដដែល ដើម្បីឱ្យសមាជិកក្រុមប្រហារមានលទ្ធភាពតម្រង់បាញ់ឱ្យបាន ត្រឹមត្រូវ រួចបញ្ជាបាញ់ដោយទំលាក់ដៃនោះចុះ។

បន្ទាប់ពីការបាញ់ប្រហារ ប្រធានក្រុមប្រហារដើម្បីកិច្ចសម្លាប់ បង្ហើយ ត្រូវយកចុងកាំភ្លើងខ្លីរបស់ខ្លួនទៅដាក់ផ្ទប់ពីខាងលើគុម្ពត្រចៀកទណ្ឌិត ហើយបាញ់តែម្ដង។ រួចប្រធានក្រុមប្រហារ ត្រូវត្រួតពិនិត្យអាវុធទាំងអស់ ព្រមទាំងរើសសំបកគ្រាប់ដែលបានបាញ់។

ក្រោយពីការបាញ់សម្លាប់បង្ហើយភ្លាម គ្រូពេទ្យត្រូវពិនិត្យអំពីមរណភាព របស់ទណ្ឌិត ហើយធ្វើនៅទីកន្លែងនោះ នូវវិញ្ញាប័ត្របញ្ជាក់ពីមរណភាពរបស់ទណ្ឌិត រួចប្រគល់ឱ្យប្រធានតុលាការ។

លុះការអនុវត្តន៍ការប្រហារជីវិតចប់សព្វគ្រប់ កងការពារប្រដាប់អាវុធលើកសពទណ្ឌិតដាក់ក្នុងមឈូស ដែលបានរៀបចំបំរុងដោយរដ្ឋអំណាចមូលដ្ឋាន និងដោយចវិការដ្ឋ។

ការកប់ ឬ បូជាសពទណ្ឌិត ត្រូវប្រព្រឹត្តឡើងជាបន្ទាន់ដោយរដ្ឋអំណាច មូលដ្ឋាន ។

នៅក្រោយពេលអនុវត្តសាលក្រមប្រហារជីវិតចប់សព្វគ្រប់ហើយ ប្រធានតុលាការត្រូវធ្វើរបាយការណ៍ស្ដីពីរឿងនោះ ហើយបញ្ជូនជាមួយកំណត់ហេតុនៃការប្រហារជីវិត ទៅជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីបានចាត់ការតាមច្បាប់។ ប្រធានតុលាការ ត្រូវផ្ញើទៅរដ្ឋអំណាចសង្កាត់ ឬ ឃុំ នូវវិញ្ញាបនប័ត្រនៃមរណភាពរបស់ទណ្ឌិត និង ពត៌មានផ្សេងៗ ដែលមានប្រយោជន៍ក្នុងការធ្វើសំបុត្រ មរណភាពនៃទណ្ឌិត។

ទ្រព្យសម្បត្តិ និង សំបុត្រដែលទណ្ឌិតបានធ្វើទុកមុនពេលប្រហារជីវិត ប្រសិនបើមាន ប្រធានតុលាការ ត្រូវប្រគល់ទ្រព្យសម្បត្តិ និង សំបុត្រនោះ ឱយទៅគ្រួសារ នៃសពទណ្ឌិត។

ករណីមានឧប្បត្តិហេតុ - ប្រសិនបើ ក្រោយពីពេលអានសាលក្រម អានសេចក្តីសំរេចបដិសេធពាក្យសុំអនុគ្រោះទោស នៅក្នុងពន្ធនាគារ ទណ្ឌិត បានធ្វើការសារភាពថ្មី ដែលមានប្រយោជន៍ធំដល់រដ្ឋ ឬក៏ទណ្ឌិតបានធ្វើឱ្យដឹង ផ្លូវឈ្មោះអ្នកប្រព្រឹត្តបទល្មើសសំខាន់ៗ ថែមទៀត ឬក៏នៅតែទទូចអំពីភាព ស្មោះត្រង់របស់ខ្លួន ដោយបង្ហាញផ្លូវភស្តុតាងថ្មី ដែលមិនអាចទាត់ចោលបាន នោះគណៈកម្មការអនុវត្តសាលក្រមប្រហារជីវិត អាចសំរេចផ្អាកជាបណ្តោះអាសន្ន នូវការអនុវត្តន៍បាន គណៈកម្មការនេះ ត្រូវធ្វើក្នុងពេលនោះភ្លាម ផ្លូវកំណត់ហេតុមួយ ប្រកបដោយហេតុបច្ច័យច្បាស់លាស់ ហើយបញ្ជូនកំណត់ហេតុ នោះជាបន្ទាន់ ទៅឱ្យរដ្ឋអំណាចមានសមត្ថកិច្ច ដើម្បីត្រួតពិនិត្យ។ ទន្ទឹមនោះ ប្រធានតុលាការ ត្រូវជូនពត៌មាននោះជាប្រញាប់ ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## III - **ការអនុវត្តន៍សាលក្រម លើទណ្ឌិត អំពីការ ដួសដុលភាពអន្តរាយ**

## **នីតិវិធីនេះ ត្រូវធ្វើឡើងជាបីបទបទ**

### **ទី ១ ÷ អំពីការឱ្យដំណឹង ដោយបង្គាប់ឱ្យ អនុវត្តសាលក្រម ដោយស្ម័គ្រចិត្ត**

ក្នុងចំណុចនេះ ជាបឋម កម្មាភិបាលតុលាការប្រជាជនទទួលបន្ទុកអនុវត្តន៍ សាលក្រម ត្រូវឱយដំណឹងដល់ទណ្ឌិតផ្ទាល់ខ្លួន ឬ ដល់ទីលំនៅរបស់ទណ្ឌិត រកំណត់ដៃសម្រង់សាលក្រមស្លាព ហើយបង្គាប់ឱយខណ្ឌិតអនុវត្តសាលក្រម ដោយស្ម័គ្រចិត្ត ក្នុងចិរវេលាកំណត់។

សេចក្តីឱ្យដំណឹងនោះ ត្រូវធ្វើជាពីរច្បាប់ មួយច្បាប់ប្រគល់ឱ្យទណ្ឌិត មួយច្បាប់ទៀត បង្វិលទៅធំកល់ទុកក្នុងសំណុំរឿង។

ប្រសិនបើផុតចិរវេលាកំណត់ហើយ ទណ្ឌិត មិនបានប្រតិបត្តិតមសាលក្រម កម្មាភិបាលតុលាការប្រជាជនទទួលបន្ទុកអនុវត្តន៍សាលក្រម អាចចេញលិខិត បង្គាប់ជាលើកទី ២ បាន ប្រសិនបើទណ្ឌិត នៅតែមិនព្រមប្រតិបត្តិតាមសាលក្រមទៀត កម្មាភិបាលតុលាការ ត្រូវធ្វើការពិនិត្យលើស្ថានភាពគ្រួសារ របស់ទណ្ឌិតដោយសហការជាមួយ

- តំណាងម្នាក់ របស់គណៈកម្មាធិការប្រជាជនបដិវត្ត សង្កាត់ ឬ ឃុំ
- តំណាងម្នាក់ របស់នគរបាលនៅមូលដ្ឋាន
- តំណាងម្នាក់ របស់មណ្ឌល ឬ ភូមិ
- តំណាងម្នាក់ របស់ក្រុម
- អ្នកជិតខាងម្នាក់

ការពិនិត្យលើស្ថានភាពគ្រួសារនេះអាចបង្ហាញចេញនូវករណី បី យ៉ាង៖

### **ក– ករណីនទណ្ឌិតស្ថិតក្នុងភាពអសោធនីយ (គ្មានទ្រព្យ ឬ គ្មានប្រាក់)**

កម្មាភិបាលតុលាការទទួលបន្ទុកអនុវត្តន៍សាលក្រម ត្រូវធ្វើកំណត់ហេតុ ដោយច្បាស់លាស់ ស្តីពីភាពអសោធនីយរបស់ទណ្ឌិត ហើយស្នើទៅប្រធាន តុលាការ ដើម្បីចេញដីកាបង្គាប់ឱ្យបញ្ឈប់ការអនុវត្តន៍សាលក្រម។

**ខ – ករណីនៃទណ្ឌិតស្ថិតក្នុងភាពសោធនីយ ក្នុងរយះកាល កំណត់ដូចជា**

**ទណ្ឌិតស្ថិតក្នុងភាពសោធនីយនៅវដ្ដវ ច្រូត កាត់ខាងមុខ**

ក្នុងករណីនេះ កម្មាភិបាលតុលាការទទួលបន្ទុកអនុវត្តន៍សាលក្រម ត្រូវស្នើ ទៅប្រធានតុលាការប្រជាជន ដើម្បីចេញដីកា ផ្អាកការអនុវត្តន៍សាលក្រម ក្នុងរយៈកាលមានកំណត់។

**គ-ករណីនៃទណ្ឌិតស្ថិតក្នុងភាពសោធនីយ តែចចេសមិនព្រមអនុវត្តសាលក្រម**

កម្មាភិបាលតុលាការទទួលបន្ទុកអនុវត្តន៍សាលក្រម ក្នុងករណីបែបនេះ ត្រូវស្នើទៅប្រធានតុលាការប្រជាជនឱ្យចេញដីកា ដើម្បីកត់ត្រារឹបអូសសទ្រព្យសម្បត្តិរបស់ទណ្ឌិតទុកមួយអន្លើ។

**បទទី ២ : អំពីអំណូសទ្រព្យសម្បត្តិទុកមួយអន្លើ**

អំណូសនេះ មានគោលដៅដាច់ខាត រឹបអូសមកទុកក្នុងកណ្ដាប់ដៃ តុលាការ នូវសម្បត្តិជាចលនវត្ថុក្តី ឬ ជាអចលនវត្ថុក្តី របស់ទណ្ឌិត ដើម្បីជៀសវាងការប្រវ៉ាញ់។ អំណូស អាចធ្វើឡើងនៅគ្រប់ដំណាក់កាល នៃនីតិវិធី ។

**ឧទាហរណ៍**: នៅដំណាក់កាលស៊ើបអង្កេត ប្រសិនបើជនរងគ្រោះ (ដើមបណ្ដឹងរដ្ឋប្បវេណី) បារម្ភអំពីសំណងដល់ភាពអន្តរាយរបស់ខ្លួន អាចស្នើសុំ ដល់អង្គការស៊ើបអង្កេត ដើម្បីចាត់វិធានការ ធ្វើអំណូសនេះបាន។ ប្រសិនបើ ទ្រព្យអំណូសនោះ ជាស្បៀងអាហារ មានលក្ខណគឆាប់ខូច អង្គការស៊ើបអង្កេត នោះអាចចាត់វិធានការលក់ស្បៀងនោះបាន ប៉ុន្តែ ត្រូវដំកល់ប្រាក់ដែលលក់បាននោះ ទុករហូតដល់មានសាលក្រមសំរេចជាស្ថាពរ។

អំណូសសទ្រព្យសម្បត្តិដែលធ្វើឡើង ដោយកម្មាភិបាលតុលាការទទួលប អនុវត្តន៍សាលក្រម ក្រៅពីលេខាធិការធ្វើកំណត់ហេតុ ត្រូវមានៈ

-តំណាងម្នាក់ របស់គណៈកម្មាធិការប្រជាជនបដិវត្ត ឃុំ ឬ សង្កាត់

-តំណាងម្នាក់ របស់នគរបាលនៅមូលដ្ឋាន

-តំណាងម្នាក់ របស់បណ្ឌល ឬ ភូមិ

-តំណាងម្នាក់ របស់ក្រុម

-អ្នកជិតខាងម្នាក់

រួមសហការជាមួយ ។

នៅទីកន្លែងធ្វើអំណូស ករណីពីរយ៉ាង អាចកើតឡើងៈ

**ក - ទ្វារបិទជាប់ : កម្មាភិបាលតុលាការទទួលបន្ទុករអនុវត្តន៍សាលក្រម**

កាលបើប្រទះករណីទ្វារបិទជាប់ដូច្នេះ ត្រូវហៅរកអ្នកឯកទេសខាងសាម្នាក់ ឬ ហៅរកប្រជាជនមួយរូប ដើម្បីជួយបើកទ្វារដែលបិទជាប់នោះនៅចំពោះមុខ តំណាង ដូចបានពោលខាងលើ។ ប្រសិនបើទ្វារទូមានចាក់សោជាប់ដែរ វិធានការដែលត្រូវចាក់ ត្រូវធ្វើតាមរបៀបខាងលើ ។

**ខ - ទ្វារចំហ ៖ ក្នុងករណីបែបនេះ កម្មាភិបាលតុលាការទទួលបន្ទុក**

អនុវត្តន៍សាលក្រម អាចចូលទៅកាន់កន្លែងអំណូសតាមធម្មតា ។

ទោះបី ការចូលទៅកាន់កន្លែងអំណូសតាមធម្មតា ឬ តាមការប្រើកម្លាំង កម្មាភិបាលតុលាការទទួលបន្ទុកអនុវត្តន៍សាលក្រម ប្រសិនបើ ទណ្ឌិតនៅទីនោះដែរ មានករណីយកិច្ចប្រាប់ជាថ្មីទៀត ឱ្យទណ្ឌិតប្រតិបត្តិតាមសាលក្រម។ ប្រសិនបើពេលនោះ ទណ្ឌិតប្រតិបត្តិតាមសាលក្រម ដោយសងនូវប្រាក់ ដែល ទណ្ឌិតត្រូវសង នោះនីតិវិធីនៃការអនុវត្តន៍សាលក្រម ត្រូវបញ្ចប់តាមច្បាប់ ដោយចុះនិទ្ទេសក្នុងកំណត់ហេតុនោះ ឱ្យបានច្បាស់លាស់។

**-ខ្លឹមសារនៃកំណត់ហេតុអំណូស**

ក្នុងកំណត់ហេតុអំណូស ត្រូវធ្វើបរមាធិប្បាយពិតប្រាកដនៃកាលៈទេសៈអំណូស សណ្ឋានហេតុដែលកើតឡើងក្នុងវេលាចាត់ការរឹបអូស ព្រមទាំងកត់ត្រា ក្នុងនោះ ដោយច្បាស់លាស់ នូវវត្ថុអំណូស គឺថា វត្ថុអំណូសនោះ ត្រូវថ្លឹង ឬ វាស់ទៅតាមប្រភេទនៃវត្ថុ។ មាស ប្រាក់ ត្បូងមានតម្លៃ ត្រូវថ្លឹង ញែកតាម ប្រភេទ និង តាមសញ្ញាចំណាំ ដែលមាននៅលើវត្ថុទាំងនោះ រួចខ្ចប់ ហើយបោះត្រាចំណាំ។

**- ការចាត់តាំងអ្នកថែរក្សាវត្ថុអំណូស**

វត្ថុអំណូសទាំងឡាយ ដើម្បីជៀសវាងការប្រវញ្ចនី (ក្រៅពីមាស ប្រាក់ ត្បូងមានតម្លៃ ដែលត្រូវប្រគល់ឱ្យធនាគារខេត្ត ឬ ក្រុង ថែរក្សាទុក) ត្រូវ ប្រគល់ឱ្យអ្នកថែរក្សាម្នាក់ ដែលចាត់តាំងឡើងក្នុងកំណត់ហេតុ ហើយអ្នក ថែរក្សារនោះ អាចជារូបទណ្ឌិតខ្លួនឯងក៏បាន។

**- ការអោយដំណឹងពីកំណត់ហេតុអំណូល**

កម្មាភិបាលតុលាការ ទទួលបន្ទុករអនុវត្តន៍សាលក្រម តាមគោលការណ៍ ត្រូវធ្វើកំណត់ហេតុអំណូស នៅទីកន្លែងអំណូស ដោយមានចុះហត្ថលេខា ពីសំណាក់កម្មាភិបាលតុលាការ និងអ្នកចូលរួម ដែលមានឈ្មោះក្នុងកំណត់ហេតុ។ កំណត់ហេតុអំណូសមួយច្បាប់ប្រគល់ឱ្យទណ្ឌិត ឬ ប្រសិនបើទណ្ឌិតមិននៅ ត្រូវប្រគល់ ឱ្យតំណាងរដ្ឋអំណាចឃុំ ឬ សង្កាត់ ដែលមានភារៈ នឹងប្រគល់ ឱ្យទណ្ឌិត។

**- ទ្រព្យសម្បត្តិដែលត្រូវរឹបអូស**

អំណូស ត្រូវធ្វើឡើងលើចលនវត្ថុ អចលវត្ថុ និងលើបំណុលរបស់ទណ្ឌិត ទោះបីទ្រព្យសម្បត្តិនោះ ស្ថិតក្នុងកណ្តាប់ដៃរបស់ទណ្ឌិតក្តី ស្ថិតក្នុងកណ្តាប់ដៃតតិយជនក្តី។ អំណូស អាចធ្វើបានត្រឹមតែធំហំនៃប្រាក់ដែលត្រូវជួសជុល ។ ប៉ុន្តែ អំណូស មិនត្រូវធ្វើឡើងលើវត្ថុ ដូចខាងក្រោមនេះ៖

- ប្រដាប់ចាំបាច់ សំរាប់ដំណេករបស់ទណ្ឌិត និង គ្រួសារនៃទណ្ឌិត

- សំលៀកបំពាក់ខានមិនបាន របស់ទណ្ឌិត និងគ្រួសារនៃទណ្ឌិត

- ហត្ថុបករណ៍ និង ឧបករណ៍ចាំបាច់ដល់ការងារ របស់ទណ្ឌិត និង គ្រួសារទណ្ឌិត

- ឧបភោគភ័ណ្ឌ និង គ្រឿងឧបភោគ-បរិភោគចាំបាច់របស់ទណ្ឌិត និង គ្រួសារទណ្ឌិត សំរាប់រស់នៅដល់រដូវច្រូតកាត់ថ្មី

- វត្ថុជាទីសក្ការប្រជា

- ប្រាក់អាហារកិច្ច

ម៉្យាងទៀត គេហដ្ឋានរបស់ទណ្ឌិត ក៏អាចជាកម្មវត្ថុ នៃអំណូសបានដែរ ប្រសិនបើ ទណ្ឌិតមានគេហដ្ឋានមួយទៀត ដែលមានភាពអាចរស់នៅបាន។

## បទទី ៣ : អំពីការលក់ទ្រព្យអំណូស

ការលក់ទ្រព្យអំណូស ត្រូវធ្វើឡើងដោយគណៈកម្មការ ដែលមានសមាសភាព ដូចតទៅៈ

| | |
|---|---|
| - តំណាងម្នាក់ ខាងពាណិជ្ជកម្មក្រុង ឬ ខេត្ត | ប្រធាន |
| - តំណាងម្នាក់ ខាងហិរញ្ញវត្ថុក្រុង ឬ ខេត្ត | សមាជិក |
| - តំណាងម្នាក់ ខាងអយ្យការ | សមាជិក |
| - កម្មាភិបាលតុលាការម្នាក់ | សមាជិក |
| - កម្មាភិបាលឯកទេសម្នាក់ | សមាជិក |

គណៈកម្មការខាងលើនេះ ត្រូវបានតែងតាំងឡើងដោយគណៈកម្មាធិការ ប្រជាជនបដិវត្តខេត្ត ឬ ក្រុង តាមសំណើរបស់ប្រធានតុលាការប្រជាជន។

គណៈកម្មការនេះ មានភារកិច្ចរួមប្រជុំ ដើម្បីកាត់តម្លៃលើទ្រព្យអំណាស តាមប្រភេទនីមួយៗ កំណត់អំពីថ្ងៃ និង វិធានការនៃការលក់ទ្រព្យរំណូសនោះ។ ម្ចាស់ទ្រព្យអំណូស (ទណ្ឌិត) អាចចូលរួបប្រជុំ និង ជូនយោបល់ដល់ គណៈកម្មការលក់ទ្រព្យអំណូសបាន ។

ការលក់ទ្រព្យអំណាស នឹងអាចប្រព្រឹត្តទៅបាន យ៉ាងតិច ៥ ថ្ងៃ ក្រោយការបិទផ្សាយបញ្ជីវាយវត្ថុដែលមានការវាយតម្លៃជាស្រេចនៅទីស្នាក់ការ តុលាការ ទីស្នាក់ការគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត ឬ ក្រុង និង នៅ ទីកន្លែងលក់ទ្រព្យអំណូស ។

នៅថ្ងៃកំណត់ការលក់ទ្រព្យរំល្វាស គណៈកម្មការ បានករណីយកិច្ចចាត់ ពិនិត្យ បញ្ជាក់ នូវទ្រព្យអំណូសឡើងវិញ។ ការពិនិត្យបញ្ជាក់ឡើងវិញនេះ មានសារៈសំខាន់ និង ដោះបន្ទុករបស់អ្នកថែរក្សា ពីកាតព្វកិច្ចរបស់គេចំពោះ ការថែរក្សាទ្រព្យអំណូស។

ក្នុងករណីដែលមានការបាត់បង ឬ មានការប្រវញ្ចនី គណៈកម្មការ ត្រូវ ធ្វើកំណត់ហេតុស្ដីពីរឿងបោះរួចធ្វើជាសំណុំរឿង បញ្ជូនទៅអង្គការមាន - សមត្ថកិច្ចជាបន្ទាន់ ។

គណៈកម្មការ មុនថ្ងៃលក់ទ្រព្យអំណូល គម្បីជូនពត៌មានអំពីការលក់នេះ ដល់គ្រួសារទណ្ឌិតដែរ។

ការលក់ទ្រព្យអំណូស ត្រូវធ្វើជាសាធារណៈ និង តាមសំបុត្របិទជិត។

ការបង់តម្លៃរបស់ ត្រូវធ្វើដោយដល់ដៃ ស្របគ្នានឹងការប្រគល់របស់ ដែលទិញបាន។

ប្រសិនបើវត្ថុណាមួយ មិនអាចរកអ្នកទិញបាន ដើមបណ្តឹងរដ្ឋប្បវេណី (ឬអ្នករងគ្រោះ) ត្រូវចាត់ទុកជាអ្នកទិញវត្ថុនោះដោយឯងៗ តាមតម្លៃ ដែលគ្រោងទុកក្នុងបញ្ជីដែលផ្សាយលក់។

គណៈកម្មការ នៃការលក់ទ្រព្យអំណូស ត្រូវចេញនយទៅអ្នកទិញ នូវ ប័ណ្ណសំគាល់ការលក់ ដែលជាលិខិតសំគាល់កម្មសិទ្ធិ។ នៅក្នុងប័ណ្ណនោះ ត្រូវចុះឈ្មោះ ទីលំនៅរបស់អ្នកទិញ តម្លៃវត្ថុ........។ល។

**កំណត់សំគាល់**

១. មិនអនុញ្ញាតជាដាច់ខាតដល់សមាជិកគណៈកម្មការ ដល់កម្មាភិបាល ដល់បុគ្គលិក ដែលរួមរៀបចំការលក់ទ្រព្យអំណូស ឬ ដល់គ្រួសារនៃអ្នកទាំងនេះ ទិញទ្រព្យអំណូសឡើយ, ទោះបីតាមមធ្យោបាយណាក៏ដោយ ។

២- ហាមមិនឱ្យយកមាស ប្រាក់ ពេជ្រ ឬ ត្បូងមានតម្លៃ ដែលជាទ្រព្យ អំណូស ទៅដាក់លក់ជាដាច់ខាត ។ រដ្ឋជាអ្នកមានសិទ្ធិទិញដោយផ្តាច់មុខ ដោយគិតតាមតម្លៃកំណត់ របស់រដ្ឋ ។

៣- ចំពោះទ្រព្យសម្បត្តិ ដែលបានរឹបអូសជាប្រយោជន៍រដ្ឋ លក្ខណៈវិនិច្ឆ័យ និង នីតិវិធីនៃការលក់ ដែលបានរអធិប្បាយខាងលើ អាចយកមកអនុវត្តបាន ។

ខ្ញុំសង្ឃឹមថា សេចក្តីណែនាំនេះ នឹងជួយដល់សមមិត្តក្នុងការបំពេញភារកិច្ច របស់សមមិត្តមិនខាន ។ ក្នុងករណីជួបការលំបាក ក្នុងការអនុវត្តន៍ ឬ ក្នុងការបកស្រាយ គប្បីសមមិត្តស្នើទៅក្រសួងយុត្តិធម៌ ។

ហត្ថលេខា និងត្រា

**អ៊ុក ប៊ុនឈឿន**

ចម្លងជូនៈ

-រដ្ឋសភា

-ក្រុមប្រឹក្សា

-ក្រុមប្រឹក្សារដ្ឋមន្ត្រី

ដើម្បីជាពត៌មាន